**មាត្រា២ :** ទទួលស្គាល់អតីតភាពការងារ និងធ្វើនិយ័តកម្មក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលចំនួន ៨២នាក់ ក្របខណ្ឌមន្ត្រីក្រមការ ចំនួន ១៤ នាក់ នៅក្រសួងមុខងារសាធារណៈ និងចាត់បញ្ចូលក្នុងឋានន្តរស័ក្តិ ៖

| ល.រ | គោត្តនាម និងនាម | | ថ្ងៃ-ខែ-ឆ្នាំ | | ឋានន្តរស័ក្តិ |
|---|---|---|---|---|---|
| | | | កំណើត | ចូលបម្រើការងារ | |
| ១ | លោកជំទាវ | ពុំ ចន្ទីនី | ០៩-០៣-១៩៥៥ | ២០-០៤-១៩៧៩ | ឧត្តមមន្ត្រីថ្នាក់លេខ ១ |
| ២ | ឯកឧត្តម | អ៊ុយ សំអាត | ០៧-០៨-១៩៥៥ | ០៩-០១-១៩៧៩ | ឧត្តមមន្ត្រីថ្នាក់លេខ ១ |
| ៣ | ឯកឧត្តម | ហួ គីមហួត | ១០-០២-១៩៥៥ | ០១-០៣-១៩៧៩ | ឧត្តមមន្ត្រីថ្នាក់លេខ ១ |
| ៤ | លោកជំទាវ | សម សូនី | ១៨-០៤-១៩៥៥ | ១៣-០៥-១៩៧៩ | ឧត្តមមន្ត្រីថ្នាក់លេខ ១ |
| ៥ | ឯកឧត្តម | អ៊ឹត ឡៅ | ០១-០៦-១៩៥៥ | ១៥-០១-១៩៧៩ | ឧត្តមមន្ត្រីថ្នាក់លេខ ២ |
| ៦ | ឯកឧត្តម | សុខ ឡុង | ០៧-០២-១៩៦៥ | ០៥-០២-១៩៩៣ | ឧត្តមមន្ត្រីថ្នាក់លេខ ៤ |
| ៧ | ឯកឧត្តម | កៀង វឌ្ឍនៈ | ០៣-០៨-១៩៥៩ | ០១-០១-១៩៧៩ | ឧត្តមមន្ត្រីថ្នាក់លេខ ៤ |
| ៨ | ឯកឧត្តម | យូ ឡាណា | ២៤-០១-១៩៦៤ | ០១-០២-១៩៨៧ | ឧត្តមមន្ត្រីថ្នាក់លេខ ៤ |
| ៩ | ឯកឧត្តម | ម៉ែន បូរីកា | ០១-០១-១៩៦៥ | ០១-១០-១៩៩១ | ឧត្តមមន្ត្រីថ្នាក់លេខ ៤ |
| ១០ | ឯកឧត្តម | សម កុសល | ០១-០២-១៩៦៣ | ០៦-០៥-១៩៩២ | ឧត្តមមន្ត្រីថ្នាក់លេខ ៤ |
| ១១ | ឯកឧត្តម | សេង ប៊ុណ្ណារា | ២០-០២-១៩៥៩ | ០១-០១-១៩៨៣ | ឧត្តមមន្ត្រីថ្នាក់លេខ ៦ |
| ១២ | ឯកឧត្តម | ថាច់ វណ្ណនី | ១១-០៥-១៩៦៤ | ០៧-០៧-១៩៨៩ | ឧត្តមមន្ត្រីថ្នាក់លេខ ៦ |
| ១៣ | លោក | វ៉ា គង្គា | ១២-១០-១៩៥៥ | ៣០-១១-១៩៧៩ | វរមន្ត្រីថ្នាក់លេខ ១ |
| ១៤ | លោក | កែវ ម៉ុន | ០១-០១-១៩៥៥ | ២៦-០២-១៩៧៩ | វរមន្ត្រីថ្នាក់លេខ ១ |
| ១៥ | លោក | សន ខឿន | ២៨-០៥-១៩៥៥ | ០៦-០៦-១៩៧៩ | វរមន្ត្រីថ្នាក់លេខ ១ |
| ១៦ | លោកស្រី | អួន ណោមមុន្នី | ៣០-០៤-១៩៥៥ | ១៤-០៥-១៩៧៩ | វរមន្ត្រីថ្នាក់លេខ ១ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS

| | | | | |
|---|---|---|---|---|
| ១៧ | លោក ទូ សេង | ១៥-០៤-១៩៥៥ | ០១-០១-១៩៧៩ | វរមន្ត្រីថ្នាក់លេខ ១ |
| ១៨ | លោក នូ សុកខន | ០៦-០៥-១៩៥៦ | ១៥-១២-១៩៧៩ | វរមន្ត្រីថ្នាក់លេខ ១ |
| ១៩ | លោក ប៊ិច សំបូរ | ០៩-១១-១៩៥៥ | ១៥-០២-១៩៧៩ | វរមន្ត្រីថ្នាក់លេខ ១ |
| ២០ | លោក ពិន ប៊ុនណ្ណារិទ្ធ | ០៣-០២-១៩៥៥ | ០១-១១-១៩៧៩ | វរមន្ត្រីថ្នាក់លេខ ១ |
| ២១ | លោកស្រី ម៉ៅ ផល្លី | ១២-០២-១៩៦៦ | ០១-០១-១៩៨៧ | វរមន្ត្រីថ្នាក់លេខ ២ |
| ២២ | កញ្ញា ឡាក់ មុនីរស្មី | ០៥-០៣-១៩៧៣ | ១៥-១២-១៩៩៩ | វរមន្ត្រីថ្នាក់លេខ ៥ |
| ២៣ | លោក ឱម វុឌ្ឍរ៉ូ | ០៧-០២-១៩៥៧ | ០១-០១-១៩៨៦ | វរមន្ត្រីថ្នាក់លេខ ៥ |
| ២៤ | លោក វ៉ា សុភ័ក្ត្រ | ១៥-១០-១៩៧០ | ០៥-០២-១៩៩៥ | វរមន្ត្រីថ្នាក់លេខ ៥ |
| ២៥ | លោក មុំ ភីរក្ស | ០៥-០៨-១៩៧៣ | ០១-០៧-១៩៩២ | វរមន្ត្រីថ្នាក់លេខ ៥ |
| ២៦ | លោក ហ្វួត ចេងឆាយ | ២០-០៣-១៩៦៩ | ០១-០៥-១៩៩៨ | វរមន្ត្រីថ្នាក់លេខ ៥ |
| ២៧ | លោកស្រី ជា សុម៉ាលី | ១២-០៤-១៩៥៥ | ០១-០១-១៩៧៩ | វរមន្ត្រីថ្នាក់លេខ ៥ |
| ២៨ | លោក អ៊ិន សុភាព | ០៧-០៤-១៩៦៥ | ០១-០១-១៩៩៤ | វរមន្ត្រីថ្នាក់លេខ ៥ |
| ២៩ | លោក ជាម ចាន់ថន | ០៧-០២-១៩៦៥ | ២៥-០៣-១៩៩១ | វរមន្ត្រីថ្នាក់លេខ ៨ |
| ៣០ | លោក ធន់ សេង | ០៥-០៣-១៩៥៥ | ១៨-០៦-១៩៧៩ | អនុមន្ត្រីថ្នាក់លេខ ១ |
| ៣១ | លោក ឌូ ផន | ០១-០១-១៩៥៥ | ១៧-០៩-១៩៧៩ | អនុមន្ត្រីថ្នាក់លេខ ១ |
| ៣២ | លោក គង់វង្ស សីហវិសាល | ០៧-០៧-១៩៦៦ | ០១-០៥-១៩៩៥ | អនុមន្ត្រីថ្នាក់លេខ ៤ |
| ៣៣ | លោកស្រី សំ វន្ថា | ២៨-០៧-១៩៨១ | ០១-០២-២០០៤ | អនុមន្ត្រីថ្នាក់លេខ ៥ |
| ៣៤ | លោក គង់ សំណាង | ០៩-១០-១៩៧២ | ០១-០៤-២០០១ | អនុមន្ត្រីថ្នាក់លេខ ៥ |
| ៣៥ | លោកស្រី យិន ប៊ុនសុភ័ក្ត្រា | ២៤-០៤-១៩៨០ | ០៥-០៤-១៩៩៩ | អនុមន្ត្រីថ្នាក់លេខ ៥ |
| ៣៦ | លោក នី ប៊ុនថា | ២៨-១២-១៩៨៤ | ១៥-០៣-២០០៦ | អនុមន្ត្រីថ្នាក់លេខ ៦ |
| ៣៧ | លោកស្រី ញ៉ឹក ស៊ីផុន | ២៤-០៩-១៩៨១ | ១៩-០១-២០០១ | អនុមន្ត្រីថ្នាក់លេខ ៦ |
| ៣៨ | លោក ផឿត សុខុន | ០៨-០៦-១៩៨៥ | ១៥-១១-២០១០ | អនុមន្ត្រីថ្នាក់លេខ ៧ |
| ៣៩ | លោកស្រី ភន គឹមហៀង | ១៥-០១-១៩៧៨ | ០១-០២-២០០៤ | អនុមន្ត្រីថ្នាក់លេខ ៧ |
| ៤០ | លោក អ៊ុយ វិចិត្រ | ១០-០៨-១៩៨០ | ១៥-០២-២០០៤ | អនុមន្ត្រីថ្នាក់លេខ ៧ |
| ៤១ | លោកស្រី នាង នារីឆាយារត្ន័ | ០១-១២-១៩៨៣ | ១៥-០២-២០០៥ | អនុមន្ត្រីថ្នាក់លេខ ៧ |
| ៤២ | លោកស្រី អ៊ូរ ចាន់ធារី | ០១-១១-១៩៨២ | ០១-១១-២០០៦ | អនុមន្ត្រីថ្នាក់លេខ ៧ |
| ៤៣ | កញ្ញា នួន រមណី | ១៨-០៥-១៩៨៣ | ០១-០៤-២០០៨ | អនុមន្ត្រីថ្នាក់លេខ ៧ |
| ៤៤ | លោកស្រី ឆន រ័ត្នចាន់ដានី | ៣០-០៤-១៩៨៤ | ០១-០៩-២០០៨ | អនុមន្ត្រីថ្នាក់លេខ ៧ |
| [illegible] | លោក ម៉ម ដារ៉ូ | ០៧-០៧-១៩៨៣ | ០១-០៨-២០០៩ | អនុមន្ត្រីថ្នាក់លេខ ៧ |
| [illegible] | លោក អ៊ឹង វិទ្យាធារ៉ា | ២៧-០៦-១៩៨៤ | ១៥-១១-២០០៩ | អនុមន្ត្រីថ្នាក់លេខ ៧ |
| [illegible] | លោក លួង លឹម | ០៧-០៨-១៩៧៥ | ០១-០១-២០០៤ | អនុមន្ត្រីថ្នាក់លេខ ៧ |

| | | | | | |
|---|---|---|---|---|---|
| ៤៨ | លោក | គិម ប៊ុនថាណា | ១៥-០២-១៩៨១ | ០១-០៦-២០១០ | អនុមន្ត្រីថ្នាក់លេខ ៧ |
| ៤៩ | លោក | អន ចំរើន | ៣០-០៣-១៩៨៤ | ០១-០៦-២០១០ | អនុមន្ត្រីថ្នាក់លេខ ៧ |
| ៥០ | លោក | ខឹម សុផល | ០១-០១-១៩៧៥ | ០១-០១-២០០៤ | អនុមន្ត្រីថ្នាក់លេខ ៨ |
| ៥១ | លោក | ទូច ភក្តី | ៣០-០៨-១៩៨៦ | ០១-០៥-២០១១ | អនុមន្ត្រីថ្នាក់លេខ ៨ |
| ៥២ | កញ្ញា | ខឹម វណ្ណថា | ១២-១០-១៩៨៧ | ០១-០៧-២០១១ | អនុមន្ត្រីថ្នាក់លេខ ៨ |
| ៥៣ | លោកស្រី | លុយ កុឡាប | ០៩-០៣-១៩៨៤ | ០១-១០-២០១១ | អនុមន្ត្រីថ្នាក់លេខ ៨ |
| ៥៤ | កញ្ញា | សេង ស្រីអូន | ១៥-០៧-១៩៨៩ | ០១-១២-២០១១ | អនុមន្ត្រីថ្នាក់លេខ ៨ |
| ៥៥ | លោក | ជា រតនៈ | ០៨-១០-១៩៨២ | ០១-០៩-២០១២ | អនុមន្ត្រីថ្នាក់លេខ ៨ |
| ៥៦ | លោកស្រី | ឌី ដារ៉ា | ១០-០៥-១៩៨៥ | ០១-០៨-២០០៧ | អនុមន្ត្រីថ្នាក់លេខ ៨ |
| ៥៧ | កញ្ញា | គេន អន | ១៩-០១-១៩៨៧ | ០១-០១-២០១៣ | អនុមន្ត្រីថ្នាក់លេខ ៨ |
| ៥៨ | លោក | ស៊ិន សុទ្ធាបញ្ញា | ៣០-០៩-១៩៩២ | ០១-១២-២០១២ | អនុមន្ត្រីថ្នាក់លេខ ៨ |
| ៥៩ | លោកស្រី | ម៉េង បុប្ផា | ០៥-០៩-១៩៨៥ | ០១-០៧-២០១៣ | អនុមន្ត្រីថ្នាក់លេខ ៨ |
| ៦០ | កញ្ញា | ពេជ្រ ចរិយា | ០៦-០២-១៩៨៦ | ១៥-១១-២០១៣ | អនុមន្ត្រីថ្នាក់លេខ ៨ |
| ៦១ | លោក | គាំ សុខាន់ | ០១-០១-១៩៧៥ | ០១-០១-១៩៩៩ | អនុមន្ត្រីថ្នាក់លេខ ៨ |
| ៦២ | លោក | ហេង សុរិសិដ្ឋ | ១៩-១២-១៩៨៨ | ០១-០៧-២០០៩ | អនុមន្ត្រីថ្នាក់លេខ ៨ |
| ៦៣ | លោក | ហូ ឡេង | ០៤-០១-១៩៦០ | ០១-០១-១៩៨៥ | អនុមន្ត្រីថ្នាក់លេខ ៨ |
| ៦៤ | លោក | អ៊ឹង សំអែល | ០២-១០-១៩៦០ | ០៧-០៣-១៩៧៩ | អនុមន្ត្រីថ្នាក់លេខ ៨ |
| ៦៥ | លោក | យឹម ហ៊ាង | ០៩-០២-១៩៦៧ | ៣០-០៨-១៩៩០ | អនុមន្ត្រីថ្នាក់លេខ ៩ |
| ៦៦ | លោក | សុខ ចាន់ត | ០១-០១-១៩៦៥ | ០១-០១-១៩៨៩ | អនុមន្ត្រីថ្នាក់លេខ ៩ |
| ៦៧ | លោក | មុត ហ៊ុយ | ១០-០៧-១៩៦៩ | ០១-០១-១៩៩១ | អនុមន្ត្រីថ្នាក់លេខ ៩ |
| ៦៨ | លោក | សេង គឿ | ០១-០១-១៩៦១ | ០១-០២-១៩៩៣ | អនុមន្ត្រីថ្នាក់លេខ ៩ |
| ៦៩ | លោក | ផង់ ប៊ុណ្ណា | ០៣-០៣-១៩៦៧ | ០១-០៣-១៩៩១ | អនុមន្ត្រីថ្នាក់លេខ ៩ |
| ៧០ | លោក | ឈិន វ៉េត | ០៥-០៥-១៩៥៩ | ០១-០៥-១៩៨៣ | អនុមន្ត្រីថ្នាក់លេខ ៩ |
| ៧១ | លោក | ញ៉ូង ស៊ិនតូ | ១០-១០-១៩៦០ | ០១-១០-១៩៧៩ | អនុមន្ត្រីថ្នាក់លេខ ៩ |
| ៧២ | លោក | គ្រី ចន្ទីរិទ្ធ | ០១-០៤-១៩៦៥ | ០១-០១-១៩៨៩ | អនុមន្ត្រីថ្នាក់លេខ ៩ |
| ៧៣ | លោក | ម៉ៅ ថាត | ០៦-១២-១៩៦៧ | ០១-០៩-១៩៩១ | អនុមន្ត្រីថ្នាក់លេខ ៩ |
| ៧៤ | លោក | វ៉ង ប៊ុនថា | ១១-០៥-១៩៦០ | ០១-០៥-១៩៨៣ | អនុមន្ត្រីថ្នាក់លេខ ៩ |
| ៧៥ | លោក | លី កើន | ២៧-០៨-១៩៦៩ | ១៥-០៧-១៩៩៥ | អនុមន្ត្រីថ្នាក់លេខ ៩ |
| [illegible] | លោក | សាំង ផល្លី | ០៩-០៦-១៩៦២ | ០១-០៤-១៩៨៤ | អនុមន្ត្រីថ្នាក់លេខ ៩ |
| [illegible] | លោក | រស់ ផុន | ០៨-១២-១៩៦៧ | ០១-០១-១៩៩១ | អនុមន្ត្រីថ្នាក់លេខ ៩ |

| | | | | | |
|---|---|---|---|---|---|
| ៧៨ | លោក | លឹម ចាន់រស្មី | ២១-០៨-១៩៨១ | ២០-០៥-២០០៥ | អនុមន្ត្រីថ្នាក់លេខ ១០ |
| ៧៩ | លោក | អ៊ិត ឬទ្ធី | ១២-០២-១៩៧២ | ០១-០១-១៩៩៦ | អនុមន្ត្រីថ្នាក់លេខ ១០ |
| ៨០ | លោក | ហែម សារាវុធ | ១៥-០៩-១៩៦៩ | ០១-០១-១៩៩៣ | អនុមន្ត្រីថ្នាក់លេខ ១១ |
| ៨១ | លោក | ជុំ សារ៉េត | ១៥-០៣-១៩៧០ | ០១-០៧-២០០៧ | អនុមន្ត្រីថ្នាក់លេខ ១១ |
| ៨២ | លោកស្រី | វ៉ា សត្យា | ០៧-០៩-១៩៨១ | ១៥-០៥-២០០៧ | អនុមន្ត្រីថ្នាក់លេខ ១៤ |
| ៨៣ | លោក | សុខ សារី | ០២-០៦-១៩៥៥ | ២៥-១០-១៩៧៩ | នាយក្រមការ ថ្នាក់លេខ ១ |
| ៨៤ | លោក | មាស សុខន | ០៧-០១-១៩៥៥ | ០១-១២-១៩៧៩ | នាយក្រមការ ថ្នាក់លេខ ១ |
| ៨៥ | លោក | គាំ ស | ០៧-០៩-១៩៥៨ | ០៧-១២-១៩៧៩ | នាយក្រមការ ថ្នាក់លេខ ១ |
| ៨៦ | លោក | ប៊ុត សាំសុង | ០៦-០៨-១៩៥៥ | ៣០-១២-១៩៧៩ | នាយក្រមការ ថ្នាក់លេខ ១ |
| ៨៧ | លោក | ប៉ាវ ឃៀង | ០៣-០១-១៩៥៥ | ០២-០២-១៩៧៩ | នាយក្រមការ ថ្នាក់លេខ ១ |
| ៨៨ | លោក | អ៊ី លឹមហួត | ២៨-០៥-១៩៥៥ | ២២-១០-១៩៧៩ | នាយក្រមការ ថ្នាក់លេខ ១ |
| ៨៩ | លោក | ឯម មី | ០១-០៧-១៩៦៤ | ០១-០២-១៩៨៨ | ក្រមការដើមខ្សែ ថ្នាក់លេខ ៣ |
| ៩០ | លោក | ពិន វង់ | ០២-០៣-១៩៧២ | ០១-០១-១៩៩៥ | ក្រមការដើមខ្សែ ថ្នាក់លេខ ៦ |
| ៩១ | លោក | អ៊ុន វី | ១៤-០២-១៩៧២ | ០១-០១-១៩៩៤ | ក្រមការដើមខ្សែ ថ្នាក់លេខ ៦ |
| ៩២ | លោក | អ៊ុន វន់ | ០៦-០២-១៩៧៥ | ០១-០៣-១៩៩៩ | ក្រមការដើមខ្សែ ថ្នាក់លេខ ៨ |
| ៩៣ | កញ្ញា | វ៉ា ស៊ីរី | ១៣-០៧-១៩៧៨ | ០១-០១-២០០៦ | ក្រមការដើមខ្សែ ថ្នាក់លេខ ១០ |
| ៩៤ | លោកស្រី | សំ ណារី | ១០-០១-១៩៦៧ | ០១-០២-១៩៩៦ | ក្រមការដើមខ្សែ ថ្នាក់លេខ ១០ |
| ៩៥ | លោកស្រី | ឯម សុម៉ាលីតា | ០៨-១០-១៩៨៨ | ០១-១២-២០០៧ | ក្រមការដើមខ្សែ ថ្នាក់លេខ ១០ |
| ៩៦ | លោកស្រី | នូ បុប្ផាម៉ាលី | ០១-០៥-១៩៧៣ | ០១-០១-២០០២ | ក្រមការដើមខ្សែ ថ្នាក់លេខ ១០ |

**មាត្រា៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤ :** សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*ចារស. ១៤០៧.២២៤*

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៤*

លេខៈ ២៤៤ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៤/២១៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ជាតិគុណបច្ចាមរណៈ

ចំពោះ

ព្រះសពព្រះគ្រូមហាធម្មញាណ ជួន អឿ

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍

៣៩៧.១៤០២.២២៥

បានប្រថាប់ព្រះរាជលញ្ឆករហើយ

ធ្វើនៅ. ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៤

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ : ០១៧/១៤ រ.ចច
រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៤
សម្តេចចៅហ្វាវាំង [illegible] អធិបតីស្រីង្គារ គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

# ព្រះរាជក្រឹត្យ

នស/រកត/០២១៤/២២០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ជូន

ក- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :
លោក ស៊ិន ច័ន្ទឆាយ៉ា
ខ- មេដាយ មាសការងារ :
លោក ឡូច មីលឡុំ

ចរល.១៤០២.២២៦

បានប្រទាំព្រះរាជលញ្ឆករហើយ

ធ្វើនៅ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៤

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ : ០១៥/១៤ រ.ចច
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៤
... អធិបតីស្រីង្គារ គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

# ព្រះរាជក្រឹត្យ

នស/រកត/០២១៤/ ២២១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្តម ពូ **សុធីរៈ** ជាទីប្រឹក្សារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **រដ្ឋមន្ត្រី** ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៤*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

ចាស.១៤០២.២២៧

លេខ ... ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ កុម្ភៈ ឆ្នាំ២០១៤
អគ្គ... រាជរដ្ឋាភិបាល

... សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០២១៤/ ២២២

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្តម **លី ផាណ្ណា** ជាទីប្រឹក្សាក្រសួងពាណិជ្ជកម្ម មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៤*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៣៩ស.១៨០២.២២៥

លេខ ... ស.ណ

សំណៅដែលមានគម្លែងជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ កុម្ភៈ ឆ្នាំ២០១៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

**ស៊យ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ១៤០,៨៤៥៩ ហិកតា នៅស្រុកតាវែង ខេត្តរតនគិរី ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ក្រុងបុក អភិវឌ្ឍន៍កៅស៊ូ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងការផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពី គោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១២៤៦ ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីទំហំ ១៤០,៨៨៥៩ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ក្រុងបុកអភិវឌ្ឍន៍កៅស៊ូ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដែល ទំហំ ១២៤,០២៨២ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះដាក់ស្តែង និងដីទំហំ ១៦,៨៥៧៧ ហិកតា រក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិជួយ ឃុំតាវែងលើ ស្រុកតាវែង ខេត្តរតនគិរី តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) និង(២) នៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះដាក់ស្តែងនៅ ភូមិជួយ ឃុំតាវែងលើ ស្រុកតាវែង ខេត្តរតនគិរី ។

**មាត្រា ៣**: ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ២៣ ក្បាលដី ជូនប្រជាពលរដ្ឋ ២១ គ្រួសារ ។

**មាត្រា ៤**: ក្នុងពេលដំណើរការវាស់វែងនិងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និង អភិបាលនៃគណៈអភិបាលខេត្តរតនគិរី ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:.៣៣..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃ សៀមប៉ាង ខេត្តស្ទឹងត្រែង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែមករា ឆ្នាំ[illegible]

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និង សត្វព្រៃសៀមប៉ាង ខេត្តស្ទឹងត្រែង ហៅកាត់ថាព្រៃការពារសៀមប៉ាង ដែលមានផ្ទៃក្រឡាទំហំ៦៦ ៩៣២ (**ប្រាំមួយម៉ឺនប្រាំមួយពាន់ប្រាំបួនរយសាមសិបពីរ**)ហិកតា ស្ថិតនៅក្នុងស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅ៖

- ការពារ អភិរក្ស និងស្តារឡើងវិញនូវធនធានសេនេទិច រុក្ខជាតិ សត្វព្រៃគ្រប់ប្រភេទ ជាពិសេសប្រភេទ ដែលកំពុងរងគ្រោះថ្នាក់ជាសាកល
- រក្សាលំនឹងមជ្ឈដ្ឋានធម្មជាតិនិងស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីដែលខូចខាត សម្រាប់ផ្តល់ជាទីជម្រកស្នាក់ អាស្រ័យ សុខសាន្តនិងការបន្តពូជរបស់ជីវៈចម្រុះគ្រប់ប្រភេទ
- ការពារប្រភពចំណីនិងថែរក្សាប្រភពទឹកឱ្យមានប្រក្រតីភាពសម្រាប់ជីវៈចម្រុះដើម្បីធានាឱ្យមាននិរន្តរភាព តំបន់ អេកូឡូស៊ី សេដ្ឋកិច្ចសង្គម និងបរិស្ថាន
- ការពារអភិរក្សសត្វត្រយងនិងសត្វព្រៃផ្សេងទៀត ពិសេសប្រភេទជិតផុតពូជ ប្រភេទដែលកំពុងទទួលរង គ្រោះថ្នាក់ និងទីជម្រកសុខសាន្តរបស់វា
- ទប់ស្កាត់និងលុបបំបាត់នូវរាល់សកម្មភាពកាប់រាន ដុត ឈូសឆាយ និងប្រែក្លាយធម្មជាតិព្រៃឈើជាដី សម្រាប់អភិវឌ្ឍដំណាំកសិកម្មឬរុក្ខជាតិប្រភេទផ្សេងក្រៅពីព្រៃឈើ
- ការពារបរិមាណស្តុកកាបូនដែលស្ថិតនៅក្នុងតំបន់ព្រៃការពារ ដើម្បីរួមចំណែកដល់ដំណើរការកាត់បន្ថយ ការសាយភាយឧស្ម័នកាបូនិចទៅក្នុងស្រទាប់បរិយាកាសនិងឈានទៅដល់ការលក់ឥណទានកាបូនព្រៃឈើ
- ទ្រទ្រង់សកម្មភាពផ្សេងៗរួមមាន ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកទេស ការអប់រំផ្សព្វផ្សាយ បណ្តុះបណ្តាល អភិវឌ្ឍសហគមន៍ ការអង្កេតតាមដានពីភាពប្រែប្រួលបរិស្ថានដែលទាក់ទងនឹង ការអភិវឌ្ឍប្រកបដោយនិរន្តរភាព
- ការពារការហូរច្រោះដី ជីជាតិដី ទីជម្រាល សម្បត្តិរូបធម៌ធម្មជាតិ អភិរក្សជីវៈចម្រុះ តុល្យភាព ប្រភពទឹក និងគុណភាពទឹក។

- រក្សាការប្រើប្រាស់ធនធានធម្មជាតិដោយសហគមន៍មូលដ្ឋាន ដើម្បីលើកស្ទួយកម្រិតជីវភាពប្រជាជនរស់នៅក្នុងឬក្បែរតំបន់និងរួមចំណែកក្នុងកម្មវិធីកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល
- រួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយនិរន្តរភាព តាមរយៈការចូលរួមគ្រប់គ្រងប្រើប្រាស់ធនធានព្រៃឈើ ដោយសហគមន៍មូលដ្ឋាន អភិវឌ្ឍគោលដៅអេកូទេសចរណ៍ និងសកម្មភាពប្រើប្រាស់ផ្សេងទៀតដែលមានផលប៉ះពាល់ទាបដល់ធនធានសេនេទិច ព្រៃឈើ និងសត្វព្រៃ។

## ជំពូកទី២
## ការកំណត់តំបន់ព្រៃការពារសៀមប៉ាង

**មាត្រា៣ .-**

តំបន់ព្រៃការពារសៀមប៉ាងមានព្រំប្រទល់ជាខ្សែព្រំបិទជិតកំណត់ដោយបណ្តាចំណុចគោលចេញពីចំណុចA ចំណុចB រហូតដល់ចំណុចP និងស្របតាមបណ្តោយខ្សែបន្ទាត់ព្រំដែនកម្ពុជា ឡាវ ដែលមាននិយាមកា៖

A(673094, 1602988) B(668737, 1602301) C(666051, 1607579) D(657731, 1597515) E(653383, 1589520) F(654415, 1580440) G(656002, 1575249) H(652531, 1570186) I(648697, 1570750) J(647967, 1576089) K(639743, 1581196) L(633984, 1581755) M(628857, 1580205) N(622533, 1581670) O(619487, 1585258) និងP(617260, 1587395)

ដូចមានផែនទីបឋមមាត្រដ្ឋាន១/២៥០ ០០០ ភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។ ចំណុចនិយាមកាទាំងនេះ ប្រើប្រាស់សម្រាប់កំណត់តំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃ សៀមប៉ាង ខេត្តស្ទឹងត្រែង ប៉ុណ្ណោះ ពុំមានឥទ្ធិពលផ្លូវច្បាប់ទៅលើការកំណត់ព្រំដែនរវាងប្រទេសនិងប្រទេសឡើយ។

**មាត្រា៤ .-**

ផ្ទៃក្រឡានៃតំបន់ព្រៃការពារសៀមប៉ាងដូចមានចែងក្នុងមាត្រា៣ខាងលើនេះ អាចធ្វើការកែប្រែបានតាមការចាំបាច់ ដោយផ្អែកលើព័ត៌មានវិទ្យាសាស្ត្រជាមូលដ្ឋាន និងស្ថានភាពជាក់ស្តែងនាពេលអនាគត។ ការកែប្រែនេះត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៣
## ការគ្រប់គ្រង

**មាត្រា៥ .-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសមត្ថកិច្ចរៀបចំនិងគ្រប់គ្រងព្រៃការពារសៀមប៉ាង ដោយសហការជាមួយក្រសួងពាក់ព័ន្ធនិងរដ្ឋបាលដែនដី ដើម្បីធានានូវការអភិវឌ្ឍធនធានធម្មជាតិប្រកបដោយនិរន្តរភាពសម្រាប់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់នោះ។

ដំណើរការនៃការរៀបចំគ្រប់គ្រងតំបន់និងអភិរក្សព្រៃការពារសៀមប៉ាង ត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទីបម្រុងភ្ជាប់ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៣៤៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៤ ស្តីពី

ការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃ "សៀមប៉ាង" ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង




បានឃើញ និង ឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អ៊ឹម ឈុនលឹម | បណ្ឌិត អ៊ុក រ៉ាប៊ុន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ២១៦,៩៣ ហិកតា នៅស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ក្នុងនោះ កាត់ចេញពីដីដែនជម្រកសត្វព្រៃបឹងពែរ និងកាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងរក្សាទុកមួយចំណែកសម្រាប់ហេដ្ឋារចនា-សម្ព័ន្ធរូបវន្ត ព្រមទាំងការផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិ-បុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/២២៩ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៤
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៥៨៧ ស.ណ.ក.ធ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ២១៦,៩៣ ហិកតា ក្នុងនោះ (១) ទំហំ ១០៨,៦៥ ហិកតា កាត់ចេញពីដីដែនជម្រកសត្វព្រៃបឹងពែរ ដោយព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/២២៩ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៤ និង (២) ទំហំ ១០៨,២៨ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋដែលទំហំ ២០៨,៥៩ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងទំហំ ៨,៣៤ ហិកតា រក្សាទុក សម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិសាគ្រាមត្បូង ឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូន គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិសាគ្រាមត្បូង ឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ។

**មាត្រា ៣**: ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ៣២៥ ក្បាលដី ជូនប្រជាពលរដ្ឋ ២១៦ គ្រួសារ នៅភូមិសាគ្រាមត្បូង ឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ។

**មាត្រា ៤**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តកំពង់ធំ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍ សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៥៧៤ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ២.៥៤៧,៦១ ហិកតា នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ក្នុងនោះ កាត់ចេញពីដីដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព និងកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន យុន សៀ អ៊ីមផត អិចផត និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ព្រមទាំងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/២៣៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៤
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិត ១៦៩៣ ឧជ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ
- លិខិត ២៣៦៤ ឧជ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១** : ត្រូវបានកាត់ដីសរុបទំហំ ២.៥៤៧,៦១ ហិកតា ក្នុងនោះ (១) ទំហំ ៤៧១,៩៧ ហិកតា កាត់ចេញពីដីដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព ដោយព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/២៣៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៤ និង (២) ទំហំ ២.០៧៥,៦៤ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ឃុន សៀ អ៊ីមផត អិចផត និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ១.៨០៦,៨៧ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះដាក់ស្តែង និងទំហំ ៧៤០,៧៤ ហិកតា មានអូរ បឹង ត្រពាំង និងរក្សាទុកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិត្រពាំងប្រាសាទ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ តាមប្រព័ន្ធកូអរដោនេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះដាក់ស្តែង នៅភូមិត្រពាំងប្រាសាទ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

**មាត្រា ៣**: ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ៥០៧ ក្បាលដី ជូនប្រជាពលរដ្ឋ ៤០៣ គ្រួសារ ។

**មាត្រា ៤**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ   សាសនា   ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៥០ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី

## ការកាត់ដីសរុបទំហំ ៣.៤១៦,១៤ ហិកតា នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្ដរមានជ័យ ក្នុងនោះ កាត់ចេញពីដីដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ទីមរីង រ៉ាប់ប៊ើរ និងកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនតៃនីញ សៀមរាបអភិវឌ្ឍន៍ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងការផ្ដល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/២៣២ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៤
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិត ១៦៩១ ឧជ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ
- លិខិត ២៣៦៧ ឧជ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីសរុបទំហំ ៣.៤១៦,១៤ ហិកតា ក្នុងនោះ (១) ទំហំ ១.២៧៤,៦៥ ហិកតា កាត់ចេញពីដីដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព ដោយព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/២៣២ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៤ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ (២) ទំហំ ៧៤២,៨២ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ទីមរឹង រ៉ាប់ប៊ើរ និង (៣) ទំហំ ១.៣៩៨,៦៧ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន តៃនីញ សៀមរាប អភិវឌ្ឍន៍ សម្រាប់ធ្វើប្រទានកម្មទំហំ ២.៦៩៣,៧៩ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងទំហំ ៧២២.៣៥ ហិកតា មានអូរ បឹង ត្រពាំង និងរក្សាទុកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិដីក្រហម ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) និង (២) នៃអនុក្រឹត្យនេះ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិដីក្រហម ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

**មាត្រា ៣**: ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ៩៣១ ក្បាលដី ជូនប្រជាពលរដ្ឋ ៥១៩ គ្រួសារ។

**មាត្រា ៤**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** [illegible] អនក្រ.បក

# អនុក្រឹត្យ

**ស្តីពី**

**ការកាត់ដីសរុបទំហំ ១.០៨០,០២ ហិកតា នៅស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ ក្នុងនោះ ចេញពីដីដែនជម្រកសត្វព្រៃបឹងពែរ និងកាត់ចេញពីដីគម្របព្រៃឈើ ឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូន ប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងការផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/២៣៤ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៤
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី ២៦ ខែកុម្ភៈឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៥៨៩ ស.ណ.ក.ធ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ១.០៨០,០២ ហិកតា ក្នុងនោះ (១) ទំហំ ៨៤៦,៣៤ ហិកតា កាត់ចេញពីដីដែនជម្រកសត្វព្រៃបឹងពែរ ដោយព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/២៣៤ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៤ និង (២) ទំហំ ២៣៣,៦៨ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋដែលទំហំ ១.០០១,១៩ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងទំហំ ៧៨,៨៣ ហិកតា រក្សាទុកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិវាលថ្នល់ ឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិវាលថ្នល់ ឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ ។

**មាត្រា ៣**: ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ៦៥៩ ក្បាលដី ជូនប្រជាពលរដ្ឋ ៣៦៥ គ្រួសារ នៅភូមិវាលថ្នល់ ឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ ។

**មាត្រា ៤:** ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥:** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការកាត់ដីទំហំ ១.៧០០,៧៣ ហិកតា នៅស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ ចេញពីដីដែនជម្រកសត្វព្រៃបឹងពែរ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងការផ្ដល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៨ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិ-បុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/២៣១ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៤
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាមី រដ្ឋបាលខេត្តព្រៃវែង និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ២០១៤

ជ.នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

ស ខេង

កន្លែងទទួល:

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- -គ្រប់ក្រសួង ស្ថាប័ន
- -រដ្ឋបាលថ្នាក់ក្រោមជាតិ
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៧ សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់ កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្ម តាមមូលដ្ឋានដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**ប្រការ១ .-**

ត្រូវបានបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានដើម្បីត្រួតពិនិត្យ និងគាំទ្រការ អនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា **នៅខេត្តបាត់ដំបង** ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ទេស ប៉ាញ** | ទីប្រឹក្សារាជរដ្ឋាភិបាល | សមាជិក |
| ២. ឯកឧត្តម **អ៊ុយ ស៊ីម** | នាយកខុទ្ទកាល័យ ឯ.ឧ ស ខេង | សមាជិក |
| ៣. ឯកឧត្តម **ឌុច សុន** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ | សមាជិក |
| ៤. ឯកឧត្តម **គុយ ប៊ុនសន** | អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ | សមាជិក |
| ៥. ឯកឧត្តម **ម៉ៅ ច័ន្ទតារា** | អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| ៦. ឯកឧត្តម **សុខ ផល** | អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| ៧. ឯកឧត្តម **ស៊ឹម សុផល** | អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| ៨. ឯកឧត្តម **ប៊ុន សេង** | មេបញ្ជាការយោធភូមិភាគទី៥ | សមាជិក |
| ៩. ឯកឧត្តម **រស់ វុណ្ណា** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ | សមាជិក |
| ១០. ឯកឧត្តម **រាជ សុភទ្ទ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ | សមាជិក |
| ១១. ឯកឧត្តម **ឌី សុភជាន** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ | សមាជិក |
| ១២. ឯកឧត្តម **សេង យូអ៊ិន** | អគ្គនាយករង នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ | សមាជិក |
| ១៣. ឯកឧត្តម **កង សុខន** | អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| ១៤. ឯកឧត្តម **សួស អង្គារ** | អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| ១៥. ឯកឧត្តម **ចៅ សុធី** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ | សមាជិក |
| ១៦. ឯកឧត្តម **កែវ សុទ្ធា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ | សមាជិក |
| ១៧. លោក **ប៉ុក សាខន** | អគ្គនាយករង នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ | សមាជិក |

| | | |
|---|---|---|
| ១៨. ឯកឧត្តម **ម៉េង ប៊ុណ្ណារិទ្ធ** | អគ្គលេខាធិការរង នៃគណៈស្ថាបត្យករកម្ពុជា | សមាជិក |
| ១៩. ឯកឧត្តម **សៀង ស៊ីតថង** | ទីប្រឹក្សាឯកឧត្តម ស ខេង | សមាជិក |
| ២០. ឯកឧត្តម **អែល សយ** | ទីប្រឹក្សាក្រសួងមហាផ្ទៃ | សមាជិក |
| ២១. ឯកឧត្តម **ទុយ ប៊ុនលី** | មេបញ្ជាការរងយោធភូមិភាគទី៥ | សមាជិក |
| ២២. ឯកឧត្តម **ឯក សំអូន** | មេបញ្ជាការរងយោធភូមិភាគទី៥ | សមាជិក |
| ២៣. លោក **សង់ ស៊ីណារ៉ុង** | អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ២៤. លោក **ធួក ដារិទ្ធ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |

**ប្រការ២ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាមី រដ្ឋបាលខេត្តបាត់ដំបង និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១៤

~~នាយករដ្ឋមន្ត្រី~~

អ.ប. ឧបនាយករដ្ឋមន្ត្រី

ស ខេង

<u>កន្លែងទទួល:</u>

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឯកឧត្តម*
*លោកជំទាវឧបនាយករដ្ឋមន្ត្រី*
*-គ្រប់ក្រសួង ស្ថាប័ន*
*-រដ្ឋបាលថ្នាក់ក្រោមជាតិ*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

ឆ្នាំទី១៤ លេខ ២១ សប្តាហ៍ទី៣ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ រាជកិច្ច ទំព័រ ២៥២៨

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាល**
**គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍**
**សម្រាប់ការបោះឆ្នោត**
លេខ.....០១ ៦៥..........

រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០១៤

# ផែនការសកម្មភាព

## ស្តីពី កិច្ចការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អាណត្តិទី ២ នៅថ្ងៃអាទិត្យទី ១៨ ខែឧសភា ឆ្នាំ២០១៤

**បទដ្ឋានគតិយុត្តជាមូលដ្ឋាន ៖**

- ច្បាប់ និងវិសោធនកម្មច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- ច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- សេចក្តីសម្រេចលេខ ៤៣ ស.ស.រ ចុះថ្ងៃទី ៣១-១០-២០១៣ របស់រាជរដ្ឋាភិបាល ស្តីពីការប្រកាសកាលបរិច្ឆេទ នៃការបោះឆ្នោត លើកទី ២ដើម្បីជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- អនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី ២២-០៩-២០១១ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិ ឆ្នាំ២០១១-២០១៤
- សេចក្តីសម្រេចលេខ ៦៦ ស.ស.រ ចុះថ្ងៃទី ០៧-១២-២០១១ របស់គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត ស្តីពីការបង្កើតលេខាធិការដ្ឋាន គ.ស.អ
- ផែនការអន្តរស្ថាប័នលេខ ០១៤ ផ.ក/១១ ចុះថ្ងៃទី ២៣-០៨-២០១១ រវាងក្រសួងមហាផ្ទៃ-ការពារជាតិ និង គ.ជ.ប ស្តីពីកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សម្រាប់ដំណើរការរៀបចំការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិ ឆ្នាំ២០១១-២០១៤
- បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌអាណត្តិទី ២ ឆ្នាំ២០១៤
- ប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី ២ ឆ្នាំ២០១៤

រាជរដ្ឋាភិបាលកម្ពុជាក្នុងនីតិកាលទី ៥ នៃរដ្ឋសភា ប្តេជ្ញាបន្តពង្រឹងការកសាងនីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស ដោយប្រកាន់ភ្ជាប់នូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស ដែលជាកត្តាសំខាន់នៃការរីកចម្រើន និងការអភិវឌ្ឍប្រទេសជាតិ ។

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ គឺជាសក្ខីភាពឆ្លុះបញ្ចាំងឱ្យឃើញកាន់តែច្បាស់អំពីសមត្ថភាព និងការបោះជំហានយ៉ាងរឹងមាំរបស់កម្ពុជាក្នុងការពង្រឹងនូវគោលការណ៍អភិបាលកិច្ចល្អ និងនីតិរដ្ឋ ការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស និងការគោរពសិទ្ធិមនុស្ស ដើម្បីជម្រុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ ប្រកបដោយចីរភាព និងបម្រើផ្ទាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងសង្គមជាតិទាំងមូល ។

អនុលោមតាមច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត( គ.ជ.ប ) បានបន្តធ្វើការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្នុងអាណត្តិទី ២ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអាទិត្យទី ១៨ ខែឧសភា ឆ្នាំ២០១៤ ហើយជាមួយគ្នានេះដើម្បីធានាបានប្រសិទ្ធភាពនៃយុទ្ធនាការការពារសន្តិសុខនៅក្នុងការបោះឆ្នោតក្រុមប្រឹក្សានេះ គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត( គ.ស.អ ) ដាក់ចេញនូវផែនការសកម្មភាព ដូចខាងក្រោម ៖

## I. គោលបំណង-សំណូមពរ

### ១. គោលបំណង

- សំដៅធានាបាននូវសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ល្អ ប្រកបដោយបរិយាកាសនយោបាយអព្យាក្រឹត ដើម្បីឱ្យដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានេះ នឹងប្រព្រឹត្តទៅដោយគ្មានការគំរាមកំហែង ការបំភិតបំភ័យ និងអំពើហិង្សា ។

- បង្កើនកិច្ចការការពារសន្តិសុខ សុវត្ថិភាពជូនដល់គ្រប់សមាសភាព និងគោលដៅសំខាន់ៗដែលពាក់ព័ន្ធនឹងការរៀបចំការបោះឆ្នោត និងការបោះឆ្នោត ។

- យកចិត្តទុកដាក់ការពារគ្រប់ទីតាំងរក្សាទុក ក្បួន ឬការដឹកជញ្ជូនសម្ភារ បរិក្ខារ និងឯកសារបោះឆ្នោត រួមមានៈ សន្លឹកឆ្នោត កំណត់ហេតុរាប់សន្លឹកឆ្នោត និងកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្នតាមការិយាល័យបោះឆ្នោតនីមួយៗ ឧបករណ៍បម្រើការបោះឆ្នោតផ្សេងៗទៀត ទៅកាន់គោលដៅនានាដែលត្រូវបានកំណត់ ។

- ពិនិត្យរៀបចំចាត់តាំងកម្លាំងនគរបាល ឬ/និង កងរាជអាវុធហត្ថ ឬកងយោធពលខេមរភូមិន្ទដែលជាមន្ត្រីអនុវត្តច្បាប់ឱ្យបំពេញភារកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោត ។

### ២. សំណូមពរ

- ក្រសួងស្ថាប័ន/អង្គភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ នៃរាជរដ្ឋាភិបាល ជាពិសេស អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ គណៈបញ្ជាការឯកភាពគ្រប់ជាន់ថ្នាក់ និងភ្នាក់ងារសន្តិសុខបោះឆ្នោតទាំងអស់ ត្រូវផ្តល់កិច្ចសហការល្អជាមួយ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ អង្គការអន្តរជាតិ អង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធ និងគណបក្សនយោបាយដែលមានឈ្មោះបោះឆ្នោត ដើម្បីបំពេញភារកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈសម្រាប់ដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាទាំងមូល ។

- អាជ្ញាធរមានសមត្ថកិច្ច មន្ត្រីអនុវត្តច្បាប់គ្រប់ប្រភេទ និងភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវធ្វើប្រតិបត្តិការដោយឈរលើគោលការណ៍នៃការគោរពសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ គោលការណ៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ព្រមទាំងនីតិវិធី ក្រមសីលធម៌របស់ គ.ជ.ប ។

## II. ខចាងការរួម

- កិច្ចការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ទូទៅ សម្រាប់គ្រប់យន្តការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា បានផ្តើមសកម្មភាពចាប់តាំងពីដើមខែមករា ឆ្នាំ២០១៤ រហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតក្រុមប្រឹក្សាជាផ្លូវការ និងការចូលកាន់តំណែងរបស់ក្រុមប្រឹក្សាថ្មីបានដំណើរការទៅចប់សព្វគ្រប់ជាស្ថាពរ ។

- ត្រូវមានវិធានការចាំបាច់នានា ដោយប្រើប្រាស់គ្រប់ជំនាញ មធ្យោបាយ និងវចនាសម្ព័ន្ធសន្តិសុខដែលមានស្រាប់ សំដៅលើកកម្ពស់ស្មារតីប្រុងប្រយ័ត្ន និងការទទួលខុសត្រូវនៅក្នុងកិច្ចការពារសន្តិសុខសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឱ្យប្រព្រឹត្តទៅប្រកបដោយជោគជ័យ បង្កើននូវប្រសិទ្ធភាពការងារបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ ឬក៏សកម្មភាពរំលោភបំពានច្បាប់ផ្សេងៗទៀត ដែលអាចនឹងបង្កឱ្យមានភាពភ័យខ្លាចក្នុងសង្គមជាតិ ឬធ្វើឱ្យប៉ះពាល់ដល់បរិយាកាសនយោបាយ និងសន្តិសុខសម្រាប់ការបោះឆ្នោតក្រុមប្រឹក្សា ។

- បន្តប្រឆាំងដាច់ខាតរាល់សកម្មភាព ឬការញុះញង់ណាមួយដែលបង្កអស្ថិរភាព ឬចលាចលក្នុងសង្គមជាតិ ដោយត្រូវទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ ដូចជាឧក្រិដ្ឋកម្មឆ្លងដែន អំពើភេរវកម្មជាតិ-អន្តរជាតិ អំពើចោរកម្ម ការឆក់ប្លន់ ឃាតកម្ម ការសម្លាតប្រាក់កខ្វក់ សកម្មភាពខុសច្បាប់ពាក់ព័ន្ធនឹងគ្រឿងញៀន និងការជួញដូរមនុស្ស ពិសេសការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ។

- បន្តជម្រុញអនុវត្តគោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាព ការពង្រឹងសុវត្ថិភាពចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈ រួមនិងការលុបបំបាត់ប៉ុស្តិ៍ត្រួតពិនិត្យមិនស្របច្បាប់ ។

## III. **ក្បាលម៉ាស៊ីនដឹកនាំកម្លាំងអនុវត្តច្បាប់**

### ១. **យន្តការដឹកនាំកម្លាំងថ្នាក់ជាតិ**

គ.ស.អ មានលេខាធិការដ្ឋានជាសេនាធិការ និងមានតួនាទី ភារកិច្ចសហការដោយផ្ទាល់ជាមួយ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីពិគ្រោះយោបល់ ឬផ្តល់ជាអនុសាសន៍ ដាក់ចេញផែនការ ផែនការសកម្មភាព និងសេចក្តីណែនាំផ្សេងៗ ដោយមានវិធានការចាំបាច់នានា ដឹកនាំបញ្ជា និងប្រើប្រាស់យន្តការដឹកនាំកម្លាំងថ្នាក់ក្រោមជាតិ ត្រួតពិនិត្យការចាត់ចែងកម្លាំង ឬមន្ត្រីអនុវត្តច្បាប់គ្រប់ប្រភេទ ដោយប្រើប្រាស់គ្រប់មធ្យោបាយ និងវចនាសម្ព័ន្ធសន្តិសុខដែលមានស្រាប់ សម្រាប់បម្រើឱ្យការងារសន្តិសុខបោះឆ្នោតទាំងមូល ។

### ២. **យន្តការដឹកនាំកម្លាំងថ្នាក់ក្រោមជាតិ**

គណៈបញ្ជាការឯកភាពរាជធានី ខេត្ត មានសិទ្ធិពេញលេញក្នុងការអនុវត្តសមត្ថកិច្ចរបស់ខ្លួនលើគ្រប់កិច្ចការការពារសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពនៅគ្រប់ដំណាក់កាល នៃការរៀបចំការបោះឆ្នោត ដោយត្រូវចាត់វិធានការចាំបាច់នានា ដឹកនាំបញ្ជាទៅគ្រប់គណៈបញ្ជាការឯកភាពក្រុង ស្រុក ខណ្ឌតាមឋានានុក្រម ត្រូវពិនិត្យការរៀបចំចាត់តាំងកម្លាំងនគរបាល ឬ/និងកងរាជអាវុធហត្ថ ឬកងយោធពលខេមរភូមិន្ទ ដែលមានមូលដ្ឋានឈរជើងក្នុងរាជធានី ខេត្តនីមួយៗ ជាភ្នាក់ងារសន្តិសុខបោះឆ្នោត ដោយត្រូវធ្វើកិច្ចសហការផ្ទាល់ជាមួយគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត( គរ/ខប ) តាមដែនសមត្ថកិច្ចរៀងៗខ្លួន ។

## IV. **ការចាត់តាំង-ការកេច្ចទទួលខុសត្រូវរបស់កម្លាំងអនុវត្តច្បាប់**

ផ្អែកតាមផែនការអន្តរស្ថាប័នមហាផ្ទៃ-ការពារជាតិ និង គ.ជ.ប ស្តីពីកិច្ចការពារសន្តិសុខសម្រាប់ការបោះឆ្នោត ឧបសម្ព័ន្ធ ១-២ ប្រធានគណៈបញ្ជាការឯកភាពរាជធានី ខេត្ត ត្រូវត្រួតពិនិត្យការចាត់តាំងកម្លាំងនគរបាលដែលមានមូលដ្ឋានឈរជើងក្នុងភូមិសាស្ត្ររបស់ខ្លួន ឱ្យបំពេញការកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោត ប៉ុន្តែក្នុងករណីខ្វះកម្លាំងនគរបាល ចំនួនដែលខ្វះនោះត្រូវបំពេញដោយកម្លាំងកងរាជអាវុធហត្ថ ឬកងយោធពលខេមរភូមិន្ទ ។

កម្លាំងភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវយកចិត្តទុកដាក់ការពារ និងផ្តល់សុវត្ថិភាពដល់បណ្តាមុខសញ្ញា និងគោលដៅសំខាន់ៗ ដែលតម្រូវឱ្យការពារជាអាទិភាព ។

### ១ **ការចាត់តាំងភ្នាក់ងារសន្តិសុខបោះឆ្នោត**

#### ១.១ ***ការរៀបចំកម្លាំងការពារការចុះឈ្មោះ-រៀបចំបញ្ជីបោះឆ្នោត***

១.១.១ កិច្ចការពារទីកន្លែងចុះឈ្មោះ និងរៀបចំបញ្ជីបោះឆ្នោត

- គោលដៅការពារ : ១.៦៣៣ ទីកន្លែងនៅតាមសាលាឃុំ សង្កាត់ ១៩៧ ក្រុង ស្រុក ខណ្ឌ
- រយៈពេលបំពេញភារកិច្ច : ២៤ ថ្ងៃ ( ពីថ្ងៃទី ១៣ កុម្ភៈ - ០៨ មីនា ២០១៤ )
- ចាត់តាំងកម្លាំងនគរបាល : ០២ នាក់ ការពារទីកន្លែងចុះឈ្មោះ-រៀបចំបញ្ជីបោះឆ្នោតនីមួយៗ ១.៦៣៣ x ០២ នាក់ = ៣.២៦៦ នាក់

១.១.២ កម្លាំងត្រៀមអន្តរាគមន៍ភូមិសាស្ត្រខាងក្រៅក្នុងក្រុង ស្រុក ខណ្ឌនីមួយៗ

- ចាត់តាំងកម្លាំងនគរបាល : ០៥ នាក់ ការពារភូមិសាស្ត្រតាមក្រុង ស្រុក ខណ្ឌនីមួយៗ ១៩៧ x ០៥ នាក់ = ៩៨៥ នាក់

**➢ សរុបចំនួនកម្លាំង ៤.២៥១ នាក់ ( សម្រាប់ការពារការចុះឈ្មោះ-រៀបចំបញ្ជីបោះឆ្នោត )**

**១.២ *ការរៀបចំកម្លាំងការពារការឃោសនាបោះឆ្នោត***

- គោលដៅការពារ : ១.៦៣៣ ឃុំ សង្កាត់ ១៩៧ ក្រុង ស្រុក ខណ្ឌ
- រយៈពេលបំពេញភារកិច្ច : ១៥ ថ្ងៃ ( ពីថ្ងៃទី ០២ - ១៦ ឧសភា ២០១៤ )
- កម្លាំងនគរបាល ដែលត្រូវចាត់តាំង គឺ
  - ក/ ប៉ុស្តិ៍នគរបាលរដ្ឋបាល : ០៧ នាក់ ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់នីមួយៗ ១.៦៣៣ x ០៧ នាក់ = ១១.៤៣១ នាក់
  - ខ/ អធិការដ្ឋាននគរបាល : ១០ នាក់ អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌនីមួយៗ ១៩៧ x ១០ នាក់ = ១.៩៧០ នាក់

**➢ សរុបចំនួនកម្លាំង ១៣.៤០១ នាក់ ( សម្រាប់ការពារការឃោសនាបោះឆ្នោត )**

**១.៣ *ការរៀបចំកម្លាំងការពារការបោះឆ្នោត-រាប់សន្លឹកឆ្នោត***

១.៣.១ កិច្ចការពារការិយាល័យបោះឆ្នោត

- គោលដៅការពារ : ១៩៧ ការិយាល័យបោះឆ្នោត ១៩៧ ក្រុង ស្រុក ខណ្ឌ
- រយៈពេលបំពេញភារកិច្ច : ០២ ថ្ងៃ ( ពីថ្ងៃទី ១៧-១៨ ឧសភា ២០១៤ )
- ចាត់តាំងកម្លាំងនគរបាល : ០៣ នាក់ ការពារការិយាល័យបោះឆ្នោតនីមួយៗ ១៩៧ x ០៣ នាក់ = ៥៩១ នាក់

១.៣.២ កម្លាំងត្រៀមអន្តរាគមន៍ភូមិសាស្ត្រខាងក្រៅក្នុងក្រុង ស្រុក ខណ្ឌនីមួយៗ

- រយៈពេលបំពេញភារកិច្ច : ០៥ ថ្ងៃ ( ពីថ្ងៃទី ១៦-២០ ឧសភា ២០១៤ )
- កម្លាំងនគរបាល ដែលត្រូវចាត់តាំង គឺ
  - ក/ ប៉ុស្តិ៍នគរបាលរដ្ឋបាល : ០៧ នាក់ ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់នីមួយៗ ១.៦៣៣ x ០៧ នាក់ = ១១.៤៣១ នាក់
  - ខ/ អធិការដ្ឋាននគរបាល : ១០ នាក់ អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌនីមួយៗ ១៩៧ x ១០ នាក់ = ១.៩៧០ នាក់

៦ សរុបចំនួនកម្លាំង ១៣.៩៩២ នាក់ ( សម្រាប់ការពារការបោះឆ្នោត-រាប់សន្លឹកឆ្នោត )

## ២ ភារកិច្ចទទួលខុសត្រូវរបស់ភ្នាក់ងារសន្តិសុខបោះឆ្នោត

### ២.១ *ដំណាក់កាលចុះឈ្មោះ-រៀបចំបញ្ជីបោះឆ្នោត*

ភ្នាក់ងារសន្តិសុខបោះឆ្នោត ដែលការពារការិយាល័យចុះឈ្មោះមានទីតាំងនៅសាលាឃុំ សង្កាត់នីមួយៗ និងកម្លាំងត្រៀមអន្តរាគមន៍ភូមិសាស្ត្រខាងក្រៅនៅតាមក្រុង ស្រុក ខណ្ឌនីមួយៗ ចាំបាច់ត្រូវសហការជាមួយនឹងគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត( គជ/ខប ) មេឃុំ ចៅសង្កាត់ និងស្មៀនឃុំ សង្កាត់ ដោយត្រូវយកចិត្តទុកដាក់អនុវត្តតាមការណែនាំ ដូចខាងក្រោម ៖

- ចាត់វិធានការការពារទីតាំងបិទផ្សាយបញ្ជីបោះឆ្នោត បញ្ជីការិយាល័យបោះឆ្នោត បញ្ជីបោះឆ្នោតដំបូង និងគ្រប់ការិយាល័យបម្រើឱ្យការងារចុះឈ្មោះបោះឆ្នោត ។
- នគរបាល ០២ នាក់ ដែលការពារការិយាល័យចុះឈ្មោះបោះឆ្នោត ត្រូវមានឯកសណ្ឋានត្រឹមត្រូវ និងត្រូវមានមុខនៅមុនម៉ោង ០៧.០០ ព្រឹក ដើម្បីពិនិត្យទីតាំងស្ថានការណ៍សន្តិសុខ និងការពារឱ្យបានតឹងរ៉ឹង ។
- ក្នុងពេលបំពេញភារកិច្ចការពារ មិនត្រូវចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោតទេ លើកលែងតែមានការស្នើសុំពីមេឃុំ ចៅសង្កាត់ និងស្មៀនឃុំ សង្កាត់ ដើម្បីឱ្យជួយដោះស្រាយរាល់បាតុភាព ឬហេតុការណ៍អសន្តិសុខអ្វីមួយ ដែលកើតមានជាយថាហេតុ ឬក៏នៅក្នុងករណីមានគ្រោះមហន្តរាយធ្ងន់ធ្ងរកើតឡើង ។
- មិនត្រូវអនុញ្ញាតឱ្យជនណាប្រដាប់អាវុធ ឬមានលាក់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងខ្លួនចូលទៅក្នុង ឬក៏ឈរក្បែរនឹងការិយាល័យចុះឈ្មោះបោះឆ្នោតបានជាដាច់ខាត ។
- ត្រូវស្ថិតនៅជិតការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីត្រៀមខ្លួនបំពេញភារកិច្ច ក្នុងករណីមានសំណូមពរពីមេឃុំ ចៅសង្កាត់ និងស្មៀនឃុំ សង្កាត់ ក្នុងគោលបំណងស្នើសុំឱ្យជួយការពារសន្តិសុខ រក្សាសណ្តាប់ធ្នាប់ និងរបៀបរៀបរយ ។
- ក្នុងករណីមានសំណូមពរពីមេឃុំ ចៅសង្កាត់ និងស្មៀនឃុំ សង្កាត់ ឬក៏នៅពេលមានគ្រោះមហន្តរាយធ្ងន់ធ្ងរកើតឡើង កម្លាំងនេះត្រូវបានបំពាក់អាវុធសមស្រប ឬ/និងភ្នាក់ងារសង្គ្រោះ( ក្រុមពន្លត់អគ្គីភ័យ ឬក្រុមបុគ្គលិកពេទ្យ ) អាចចូលទៅជួយធ្វើអន្តរាគមន៍ ឬក៏ជួយសង្គ្រោះនៅពេលនោះបាន ។
- នគរបាលដែលជាកម្លាំងត្រៀមអន្តរាគមន៍ភូមិសាស្ត្រខាងក្រៅ ចំនួន ០៥ នាក់ ឈរជើងនៅក្នុងក្រុង ស្រុក ខណ្ឌនីមួយៗ ត្រូវយកចិត្តទុកដាក់ការពារផ្តល់សុវត្ថិភាពដល់បណ្តាមុខសញ្ញា និងគោលដៅសំខាន់ៗដែលបានកំណត់ជាអាទិភាព ដោយត្រូវតាមដាន ក្តាប់ជាប់សភាពការណ៍សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់នៅក្នុងភូមិសាស្ត្រឈរជើងរបស់ខ្លួន ដោយត្រៀមលក្ខណៈរួចជាស្រេច សម្រាប់ការចូលរួមជួយអន្តរាគមន៍ឱ្យបានទាន់ពេលវេលា ចំពោះរាល់ហេតុការណ៍ ឬឧបទ្ទវហេតុផ្សេងៗដែលអាចកើតមានជាចៃដន្យ ។
- បន្ទាប់ពីការរៀបចំបញ្ជីបោះឆ្នោតត្រូវបានបញ្ចប់ ត្រូវប្រមូលផ្តុំកម្លាំងទាំងអស់ និងបន្តត្រៀមលក្ខណៈនៅតាមអង្គភាព ឬគោលដៅដែលបានកំណត់ ចាប់ពីក្នុងអំឡុងពេល នៃដំណើរការនីតិវិធីដោះស្រាយបណ្តឹងទាក់ទងការចុះឈ្មោះបោះឆ្នោត និងបញ្ជីបោះឆ្នោតដំបូង រហូតដល់ចប់ការផ្តល់សុពលភាព និងការបិទផ្សាយបញ្ជីបោះឆ្នោតជាផ្លូវការសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

### ២.២ *ដំណាក់កាលឃោសនាបោះឆ្នោត*

ក្នុងអំឡុងពេលនៃយុទ្ធនាការឃោសនាបោះឆ្នោត ផ្អែកតាមសំណើ និងប្រតិទិនដាក់ស្តែងសម្រាប់សកម្មភាពឃោសនារបស់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត នៅក្នុងមូលដ្ឋានរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់នីមួយៗ គឺត្រូវចាត់ចែងកម្លាំងនគរបាលដូចបានកំណត់ខាងលើ ដើម្បីឱ្យការពារគ្រប់ទីតាំង ឬក្បួន

ឃោសនាបោះឆ្នោត និងជុំវិញបរិវេណ នៃអង្គពិធីឃោសនា ដោយរក្សាឱ្យបាននូវបរិយាកាសនយោបាយអព្យាក្រឹត គ្មានការបំភិតបំភ័យ ការគំរាមកំហែង និងអំពើហិង្សា ឬក៏ការបង្កនូវការអុកឡុករំខាន ឬចលាចលផ្សេងៗ ។

ភ្នាក់ងារសន្តិសុខបោះឆ្នោត មិនត្រូវទៅឈរក្បែរ ឬដើរកៀកពេកនឹងទីតាំង ឬក្បួនឃោសនាបោះឆ្នោត ឬក៏ស្ថិតនៅក្នុងបរិវេណ នៃអង្គពិធី និងមធ្យោបាយឃោសនា ដោយត្រូវធានាចំពោះបេក្ខជនគ្រប់រូប ឬគ្រប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនូវសិទ្ធិស្មើៗគ្នា ក្នុងការទទួលបាននូវសេវាសន្តិសុខ សុវត្ថិភាព រួមនិងការរៀបចំសណ្តាប់ធ្នាប់របៀបរៀបរយពីអាជ្ញាធរមានសមត្ថកិច្ច នៃរាជរដ្ឋាភិបាល ។

ភ្នាក់ងារសន្តិសុខបោះឆ្នោតដែលកំពុងបំពេញភារកិច្ច ត្រូវប្រកាន់ជំហរអព្យាក្រឹត ដោយមិនត្រូវចូលរួម ឬក៏ប្រឆាំងចំពោះសកម្មភាពឃោសនាបោះឆ្នោតរបស់បេក្ខជន ឬគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតណាមួយជាដាច់ខាត ។

### ២.៣ *ដំណាក់កាលបោះឆ្នោត-រាប់សន្លឹកឆ្នោត*

ភ្នាក់ងារសន្តិសុខបោះឆ្នោត ចំនួន ០៣ នាក់ ដែលមានពាក់ប៉ានដៃសន្តិសុខរបស់ គ.ជ.ប ត្រូវទៅកាន់ការិយាល័យបោះឆ្នោត ឱ្យបានមុនពេលចាប់ផ្តើមការបោះឆ្នោត ដើម្បីពិនិត្យទីតាំង និងស្ថានការណ៍សន្តិសុខឱ្យបានគ្រប់ជ្រុងជ្រោយ ដោយត្រូវអនុវត្តតាមគោលការណ៍ ដូចតទៅ ៖

- មិនត្រូវជ្រៀតជ្រែកការងារបោះឆ្នោត ឬចូលទៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដោយគ្មានការអនុញ្ញាតក្នុងពេលបោះឆ្នោត ឬរាប់សន្លឹកឆ្នោត លើកលែងតែមានការស្នើសុំពីប្រធានការិយាល័យដើម្បីអន្តរាគមន៍ ឬដោះស្រាយរាល់បាតុភាព ការអុកឡុក ឬការរំខានផ្សេងៗ ។
- មិនត្រូវអនុញ្ញាតឱ្យជនណាប្រដាប់អាវុធ ឬមានលាក់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងខ្លួនចូលទៅក្នុង ឬក៏ឈរក្បែរការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតបានជាដាច់ខាត ។
- ត្រូវស្ថិតនៅជិតការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដើម្បីត្រៀមខ្លួនបំពេញភារកិច្ចនៅក្នុងករណីមានសំណូមពរពីប្រធានការិយាល័យ ក្នុងគោលបំណងស្នើសុំឱ្យជួយការពារសន្តិសុខ សណ្តាប់ធ្នាប់ និងការរៀបចំរបៀបរៀបរយ ។
- ករណីមានសំណូមពរពីប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬករណីមានគ្រោះមហន្តរាយធ្ងន់ធ្ងរជាក់ស្តែង កម្លាំងអាចត្រូវបានបំពាក់អាវុធសមស្រប ឬភ្នាក់ងារសង្គ្រោះ( ក្រុមពន្លត់អគ្គីភ័យ ឬក្រុមបុគ្គលិកពេទ្យ ) អាចចូលជួយធ្វើអន្តរាគមន៍ ឬក៏សង្គ្រោះនៅក្នុងការិយាល័យកើតហេតុបាន ។

### ២.៤ *កិច្ចការការពារសម្ភារ-បរិក្ខារ-ឯកសារបោះឆ្នោត និងការដឹកជញ្ជូន*

តាមការស្នើសុំពី គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវយកចិត្តទុកដាក់ចាត់ចែងកម្លាំងភ្នាក់ងារសន្តិសុខ ឱ្យចូលរួមការពារគ្រប់ទីកន្លែងរក្សាទុក ក្បួន ឬការដឹកជញ្ជូនសម្ភារ បរិក្ខារ និងឯកសារបោះឆ្នោត ដូចជា : សន្លឹកឆ្នោត កំណត់ហេតុរាប់សន្លឹកឆ្នោត និងកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្នតាមការិយាល័យបោះឆ្នោតនីមួយៗ និងឧបករណ៍បម្រើការបោះឆ្នោតផ្សេងៗទៀតពីគោលដៅមួយទៅកាន់គោលដៅមួយដែលត្រូវបានកំណត់ ។

## V. **ការងារធំនាក់ធំនងផ្សេងៗ**

គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ត្រូវមានកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលឱ្យបានជាប់ជាប្រចាំជាមួយនិង គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ និងសង្គមស៊ីវិល មានអង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ សមាគម និងគណបក្សនយោបាយលើការងារខាងវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់ទូទៅនៅក្នុងអំឡុងពេល នៃដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

ប្រធានគណៈបញ្ជាការឯកភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ស្នងការនគរបាលរាជធានី ខេត្ត ឬមន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធដទៃទៀត ត្រូវមានគំនិតផ្តួចផ្តើមរៀបចំជាកិច្ចប្រជុំរួម និងត្រូវចូលរួម ឬក៏ចាត់តាំងតំណាងឱ្យចូលរួមក្នុងគ្រប់កិច្ចប្រជុំតាមការកំណត់របស់ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ក្នុងគោលដៅដើម្បីចាត់វិធានការបង្ការ ទប់ស្កាត់រាល់បញ្ហាទំនាស់ និងការដោះស្រាយទំនាស់ ឬក៏បញ្ហាផ្សេងៗ ដែលទាក់ទងនឹងដំណើរការនៃការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាអាណត្តិទី ២ នេះ ។

គណៈបញ្ជាការឯកភាពរាជធានី ខេត្ត និងស្នងការនគរបាលរាជធានី ខេត្ត ត្រូវរាយការណ៍ជាប្រចាំជុំវិញស្ថានការណ៍សន្តិសុខ និងអំពីសកម្មភាពអនុវត្តការងាររបស់ខ្លួន ជូនថ្នាក់ដឹកនាំនៃ គ.ស.អ តាមរយៈលេខាធិការដ្ឋាន ឬអគ្គស្នងការដ្ឋាននគរបាលជាតិឱ្យបានទៀងទាត់ និងទាន់ពេលវេលាចាប់ពីពេលនេះតទៅ ។

ផ្អែកតាមផែនការសកម្មភាពនេះ លេខាធិការដ្ឋាន គ.ស.អ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ អគ្គស្នងការដ្ឋាននគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធ និងគណៈបញ្ជាការឯកភាពរាជធានី ខេត្ត ត្រូវពិនិត្យរៀបចំជាផែនការសកម្មភាព យោងតាមតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន ដើម្បីចាត់ចែងអនុវត្តភារកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាលើកទី ២ ឱ្យមានប្រសិទ្ធិភាពខ្ពស់ និងទទួលបានជោគជ័យ ។/.

**ប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍**
**សម្រាប់ការបោះឆ្នោត**

**ស ខេង**

**__កន្លែងទទួល__ ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋាន គ.ជ.ប
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

« ដើម្បីជូនជ្រាប »
- អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ
- លេខាធិការដ្ឋាន គ.ស.អ
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- គណៈបញ្ជាការឯកភាពរាជធានី ខេត្ត

« ដើម្បីអនុវត្ត »
- ឯកសារ-កាលប្បវត្តិ (SSD)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ.....២៥០.......សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាគោលនយោបាយ នៃមូលនិធិទ្រទ្រង់និងអភិវឌ្ឍវិស័យកសិកម្ម

## រដ្ឋមន្ត្រី

## ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ខែកញ្ញាឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិទ្រទ្រង់និងអភិវឌ្ឍវិស័យកសិកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ កំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាគោលនយោបាយ នៃមូលនិធិទ្រទ្រង់និងអភិវឌ្ឍវិស័យកសិកម្ម ដែលសរសេរជាអក្សរកាត់ថា “**គ.គ.គ.**”។

**ប្រការ២.-**

**គ.គ.គ.** មានសមាសភាពដូចខាងក្រោម ÷

| | |
|---|---|
| ១-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២-ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | អនុប្រធាន |
| ៣-តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៤-តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៥-តំណាងវិស័យឯកជនក្នុងវិស័យកសិកម្ម | សមាជិក |
| ៦-អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | លេខាធិការ។ |

សមាសភាពជាក់ស្តែងនៃ**គ.គ.គ.**ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៣.-**

**គ.គ.គ.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម÷

- កំណត់គោលនយោបាយក្នុងការប្រើប្រាស់ឥណទានសម្រាប់ជួយទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ស្វែងរកធនធានហិរញ្ញវត្ថុពីប្រភពផ្សេងៗ ដើម្បីបង្កើនទៅក្នុងមូលនិធិទ្រទ្រង់និងអភិវឌ្ឍវិស័យកសិកម្ម
- កំណត់អត្រាការប្រាក់លើការផ្តល់ឥណទានរយៈពេលខ្លី មធ្យម និងវែងដល់សមាគម សហគមន៍ ឬក្រុមហ៊ុនកែច្នៃស្រូវ-អង្ករ កសិផល និងអនុផលផ្សេងទៀតពីប្រជាកសិករ តាមតម្លៃមួយសមរម្យ ដើម្បីធានាស្ថិរភាពថ្លៃ និងសន្តិសុខស្បៀង ព្រមទាំងដើម្បីពង្រីកសមត្ថភាពនិងគុណភាពនៃការកែច្នៃផលិតផលកសិកម្មដែលបម្រើសេចក្តីត្រូវការក្នុងស្រុក និងការនាំចេញ
- ពិនិត្យនិងវាយតម្លៃលើរបាយការណ៍នៃការប្រើប្រាស់មូលនិធិទ្រទ្រង់និងអភិវឌ្ឍវិស័យកសិកម្ម ដើម្បីរាយការណ៍តាមការចាំបាច់ ជូនរាជរដ្ឋាភិបាល និងស្នើសុំដាក់ចេញវិធានការសម្រាប់អនុវត្តបន្ត
- គ្រប់គ្រងរាល់ចំណូល-ចំណាយ ពាក់ព័ន្ធនឹងការគ្រប់គ្រងប្រតិបត្តិការ នៃមូលនិធិទ្រទ្រង់និងអភិវឌ្ឍវិស័យកសិកម្ម។

**ប្រការ៤.-**

គ.គ.ភ. រៀបចំកិច្ចប្រជុំ មួយត្រីមាសម្តង និងអាចរៀបចំកិច្ចប្រជុំពិសេស ឬបន្ទាន់ ក្នុងករណីចាំបាច់ តាមការសម្រេចរបស់ប្រធាន គ.គ.ភ.។

សមាជិក គ.គ.ភ. ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន។

ប្រធាន គ.គ.ភ. មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ចូលរួមប្រជុំ តាមការចាំបាច់។

សមាជិកចូលរួមប្រជុំ គ.គ.ភ. អាចទទួលបានលាភការសម្រាប់ការចូលរួមកិច្ចប្រជុំនីមួយៗរបស់ គ.គ.ភ.។ លាភការនេះត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៥.-**

គ.គ.ភ. មានលេខាធិការដ្ឋានមួយ ជាសេនាធិការ សម្រាប់ដំណើរការនៃការងាររបស់ខ្លួន។

នាយកដ្ឋានទីផ្សារនិងស្ថាប័នហិរញ្ញវត្ថុ នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបំពេញមុខងារជាលេខាធិការដ្ឋានរបស់ គ.គ.ភ.។

**ប្រការ៦.-**

ប្រកាសលេខ ១១១៧ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាគោលនយោបាយនៃមូលនិធិទ្រទ្រង់និងអភិវឌ្ឍវិស័យកសិកម្ម និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការ និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសមាសភាពដូចមានចែងក្នុងប្រការ២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..០០៥........សហវ.....

# សារាចរណែនាំ
## ស្តីពី
## ការពង្រឹងការគ្រប់គ្រងការធ្វើអាជីវកម្ម សេវាកម្ម ទ្រព្យសម្បត្តិរបស់រដ្ឋ

កន្លងមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានសង្កេតឃើញថា ក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានរបស់សាលារាជធានី ខេត្ត ក្នុងការគ្រប់គ្រងអាជីវកម្ម សេវាកម្មទ្រព្យសម្បត្តិរបស់រដ្ឋ ដូចជា ផ្សារ កំពង់ចម្លង ចំណត យៀត្រី សត្តឃាតដ្ឋាន សេវាប្រមូលសំអាតនិងដឹកជញ្ជូនសំរាម និងការផ្តល់សម្បទានរបស់រដ្ឋដទៃទៀត បានប្រព្រឹត្តទៅនៅមានកម្រិតនៅឡើយ ។ ទន្ទឹមនោះ ក៏នៅមានចំណុចខ្វះខាតមួយចំនួនទៀត ដូចជា ការមិនបានកត់ត្រាទ្រព្យសម្បត្តិទាំងនោះក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ការគ្រប់គ្រង និងការប្រមូលចំណូលមិនបានល្អ ដោយបណ្តែតបណ្តោយឲ្យភាគីឯកជន ដែលជាអ្នកទទួលសិទ្ធិពីរដ្ឋយកតម្លៃភាស៊ី សេវាពីអាជីវករ និងប្រជាពលរដ្ឋលើសពីការកំណត់នៅក្នុងសៀវភៅបន្ទុក ព្រមទាំងប្រកាន់អាកប្បកិរិយាមិនសមរម្យមកលើប្រជាពលរដ្ឋដែលប្រើប្រាស់សេវាទាំងនេះ ។ ប្រការនេះបណ្តាលឲ្យកើតចេញជាទំនាស់ និងការថ្នាំងថ្នាក់ដល់ប្រជាពលរដ្ឋទូទៅ និងអាជីវករជាញឹកញាប់ ហើយកាន់តែពិបាកដោះស្រាយ ។

សារាចរណែនាំនេះ មានគោលបំណងកែលំអការគ្រប់គ្រងឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀតលើអ្នកទទួលសិទ្ធិពីរដ្ឋក្នុងការធ្វើអាជីវកម្ម និងផ្តល់សេវាកម្មដល់ប្រជាពលរដ្ឋ និងអាជីវករ ដែលជាអ្នកប្រើប្រាស់សេវាកម្ម ដូចជា ផ្សារ កំពង់ចម្លង ចំណត យៀត្រី សត្តឃាតដ្ឋាន សេវាប្រមូលសំអាតនិងដឹកជញ្ជូនសំរាម និងការផ្តល់សម្បទានរបស់រដ្ឋដទៃទៀត ។ ជាមួយនេះ សារាចរណែនាំក៏មានគោលបំណងធ្វើវិមជ្ឈការនិងវិសហមជ្ឈការ នូវសិទ្ធិអំណាចនៃការគ្រប់គ្រង និងការចាត់ចែងមួយចំនួនទៀតពីថ្នាក់កណ្តាលទៅថ្នាក់ក្រោមជាតិ ដើម្បីឲ្យបង្កើនប្រសិទ្ធភាពនៃការទទួលខុសត្រូវបន្ថែមទៀត លើការផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋ និងអាជីវករទាំងអស់នៅគ្រប់ទីកន្លែង។

ដើម្បីពង្រឹង កែលំអ និងបង្កើនការទទួលខុសត្រូវលើការគ្រប់គ្រងធ្វើអាជីវកម្ម សេវាកម្មលើទ្រព្យសម្បត្តិរបស់រដ្ឋ និងការផ្តល់សម្បទានរបស់រដ្ឋដទៃទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំចំពោះសាលារាជធានី ខេត្ត ព្រមទាំងនីតិបុគ្គល និងរូបវន្តបុគ្គលពាក់ព័ន្ធ ដូចតទៅ៖

### I-គោលការណ៍សម្រាប់ដាក់ធ្វើអាជីវកម្ម សេវាកម្ម

១-រាល់ការចាត់ចែងលើទ្រព្យសម្បត្តិរបស់រដ្ឋ រួមមាន ផ្សារ កំពង់ចម្លង ចំណត យៀត្រី សត្តឃាតដ្ឋាន សេវាប្រមូលសំអាតនិងដឹកជញ្ជូនសំរាម និងការផ្តល់សម្បទានរបស់រដ្ឋដទៃទៀត សាលា



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

រាជធានី ខេត្ត ត្រូវបង្កើតគណៈកម្មការសម្រាប់ការត្រួតពិនិត្យសិក្សាវាយតម្លៃទីតាំងសម្រាប់ការវិនិយោគ ការជួលកន្លែងលក់ដូរក្នុងផ្សារ រួមទាំងទីតាំងត្រូវវិនិយោគថ្មីរបស់ឯកជន ដែលដាក់ឱ្យបម្រើសេវាសាធារណៈ ។

២-ករណីមានគម្រោងអភិវឌ្ឍកែលំអ ជួសជុល សាងសង់ វិនិយោគលើទ្រព្យសម្បត្តិរបស់រដ្ឋ និងការផ្តល់សម្បទានរបស់រដ្ឋដទៃទៀត សាលារាជធានី ខេត្ត ពិនិត្យ និងសម្រេចផ្តល់គោលការណ៍ឲ្យអ្នកវិនិយោគ ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នកពិនិត្យ និងសម្រេចតែលើផ្នែកហិរញ្ញវត្ថុ ។

៣-ការដេញថ្លៃប្រចាំឆ្នាំសម្រាប់ធ្វើអាជីវកម្ម សេវាកម្ម ត្រូវរៀបចំលិខិតបទដ្ឋានតាមនីតិវិធីដេញថ្លៃជាសាធារណៈជារៀងរាល់ឆ្នាំ ។ គណៈកម្មការខាងលើ មានភារកិច្ចសិក្សាកំណត់ថ្លៃមូលដ្ឋានសម្រាប់ដាក់ឲ្យដេញថ្លៃជាសាធារណៈ ។ សាលារាជធានី ខេត្ត ត្រូវលើកសំណើសុំការសម្រេចពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីកំណត់ថ្លៃមូលដ្ឋាន និងពេលវេលាដាក់ឲ្យដេញថ្លៃតាមនីតិវិធីជាធរមាន ។

៤-ក្រោយពីដេញថ្លៃរួចរាល់ចប់ជាស្ថាពរ សាលារាជធានី ខេត្ត មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត មន្ទីរជំនាញ និងអ្នកដេញថ្លៃបាន ត្រូវចុះហត្ថលេខាលើកំណត់ហេតុដេញថ្លៃ សៀវភៅបន្ទុក ឬកិច្ចសន្យា ដើម្បីអនុវត្តធ្វើអាជីវកម្មសេវាកម្មនេះ ។

៥-គណៈកម្មការនេះ មានភារកិច្ចក្នុងការរៀបចំចុះបញ្ជីលើមុខសញ្ញាទ្រព្យសម្បត្តិរបស់រដ្ឋ (ទីតាំងរបស់រដ្ឋ ទីតាំងវិនិយោគថ្មីរបស់ភាគីឯកជន) នៅរៀងរាល់មួយឆ្នាំម្តងឲ្យបានរួចរាល់ជាស្ថាពរយ៉ាងយូរត្រឹមថ្ងៃទី៣០ ខែមករានៃឆ្នាំបន្ទាប់ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ) ឲ្យបានទៀងទាត់ ។

## II-យន្តការ និងនីតិវិធីក្នុងការដាក់ឲ្យដេញថ្លៃ

### ក-ការរៀបចំ

១-សាលារាជធានី ខេត្ត ត្រូវធ្វើសេចក្តីជូនដំណឹងផ្សព្វផ្សាយរួមទាំងសៀវភៅបន្ទុកជាសាធារណៈតាមរយៈ វិទ្យុ ទូរទស្សន៍ សារពត៌មាន ការបិទផ្សាយនៅតាមស្ថាប័នរដ្ឋ ឬនៅទីសាធារណៈសំខាន់ៗឲ្យបានយ៉ាងតិច ១៥ថ្ងៃ មុនពេលដាក់ឲ្យដេញថ្លៃជាសាធារណៈ ។ ករណីគ្មានអ្នកដាក់ពាក្យចូលរួមដេញថ្លៃ សាលារាជធានី ខេត្ត ត្រូវពន្យារពេលផ្សព្វផ្សាយពីការដេញថ្លៃរយៈពេល ១០ថ្ងៃ បន្ថែមទៀត ។

២-នីតិបុគ្គល ឬ រូបវន្តបុគ្គល ប្រជាពលរដ្ឋទាំងពីរភេទមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ លើកលែងតែមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ សិស្ស និស្សិត មានសិទ្ធិចូលរួមដេញថ្លៃ ដោយត្រូវបំពេញសំណុំបែបបទសុំចូលរួមដេញថ្លៃតាមសេចក្តីជូនដំណឹង ។

៣-នីតិបុគ្គល ឬ រូបវន្តបុគ្គល ដែលបានដាក់ពាក្យសុំចូលដេញថ្លៃ មិនបានចូលដេញថ្លៃ ដោយគ្មានមូលហេតុ ឬក្នុងមូលហេតុដែលមិនអាចទទួលយកបាន ឬប្រកែកពុំព្រមចូលដេញថ្លៃ នោះប្រាក់កក់បណ្តោះអាសន្នត្រូវបានរឹបអូសជាប្រយោជន៍ថវិការាជធានី ខេត្ត ។ ក្នុងករណីសាមីខ្លួនអវត្តមានដោយមូលហេតុចាំបាច់ណាមួយ ត្រូវធ្វើលិខិតប្រគល់សិទ្ធិឲ្យតំណាងរបស់ខ្លួនចូលរួមដេញថ្លៃជំនួស ដោយមានការបញ្ជាក់ពីមេឃុំ ឬចៅសង្កាត់ ហើយត្រូវមានការឯកភាពពីប្រធានគណៈកម្មការដេញថ្លៃនៅពេលនោះ ។

៤-សាលារាជធានី ខេត្ត ត្រូវបង្កើតគណៈកម្មការសម្រាប់ការដេញថ្លៃ ដែលមានសមាសភាពដូចមានចែងក្នុងសៀវភៅបន្ទុក។

**ខ-វិធីសាស្ត្រនៃការដេញថ្លៃ**

១-ការដេញថ្លៃសម្រាប់ការធ្វើអាជីវកម្ម សេវាកម្ម លើទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវអនុវត្តតាមរូបភាពដេញថ្លៃឡើង ដោយដាក់ក្នុងស្រោមសំបុត្រជា ៣លើក ។

២-ក្រោយពីអនុវត្តនីតិវិធីដេញថ្លៃប្រព្រឹត្តទៅចប់សព្វគ្រប់ សាលារាជធានី ខេត្ត (គណៈកម្មការសម្រាប់ការដេញថ្លៃ) ត្រូវរៀបចំកំណត់ហេតុស្តីពីលទ្ធផលនៃការដេញថ្លៃ ។

**គ-ការរៀបចំសៀវភៅបន្ទុក ឬកិច្ចសន្យា**

១-បន្ទាប់ពីទទួលបានលទ្ធផលស្ថាពរ នៃការដេញថ្លៃជាសាធារណៈ សម្រាប់ការធ្វើអាជីវកម្ម សេវាកម្ម ប្រចាំឆ្នាំ ឬមានគោលការណ៍ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុហើយនោះ សាលារាជធានី ខេត្ត ត្រូវរៀបចំសៀវភៅបន្ទុក ឬកិច្ចសន្យា ដោយចុះហត្ថលេខា ទទួលខុសត្រូវពីមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត សាមីអង្គភាពពាក់ព័ន្ធ និងភាគីឯកជន ដែលមានការឯកភាពពីឯកឧត្តមអភិបាលរាជធានី ខេត្ត ។

២-គំរូសៀវភៅបន្ទុក ឬកិច្ចសន្យា ត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ឃ-ការអនុវត្ត**

១-សាលារាជធានី ខេត្ត ត្រូវបង្កើតគណៈកម្មការត្រួតពិនិត្យការអនុវត្តសៀវភៅបន្ទុក ឬកិច្ចសន្យាថ្នាក់រាជធានី ខេត្ត ដែលឯកឧត្តមអភិបាលខេត្ត ឬតំណាង ជាប្រធាន លោកប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ជាអនុប្រធានអចិន្ត្រៃយ៍ លោកប្រធានមន្ទីរជំនាញពាក់ព័ន្ធ ឬតំណាង ជាអនុប្រធាន សមត្ថកិច្ចពាក់ព័ន្ធ ជាសមាជិក និងប្រធានការិយាល័យទ្រព្យសម្បត្តិរដ្ឋនៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ជាលេខាកត់ត្រា ។

២-ក្នុងករណីចាំបាច់ សាលាខណ្ឌ ក្រុង ស្រុក អាចបង្កើតអនុគណៈកម្មការត្រួតពិនិត្យការអនុវត្តសៀវភៅបន្ទុក ឬកិច្ចសន្យា លើទីតាំងភូមិសាស្ត្ររដ្ឋបាលរបស់ខ្លួន ។ អនុគណៈកម្មការនេះ ជាសេនាធិការជូនគណៈកម្មការថ្នាក់រាជធានី ខេត្ត ដែលមានការឯកភាពពីសាលារាជធានី ខេត្ត ។

៣-រាល់គម្រោងវិនិយោគអភិវឌ្ឍកែលំអ ជួសជុល សាងសង់ ដែលអនុវត្តបានតាមពេលវេលាកំណត់ដូចមានចែងក្នុងសៀវភៅបន្ទុក ឬកិច្ចសន្យា ត្រូវមានកំណត់ហេតុវាយតម្លៃរបស់គណៈកម្មការចម្រុះរាជធានី ខេត្ត ដោយមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យលើគុណភាព និងបរិមាណ ដោយផ្ទៀងផ្ទាត់តាមគម្រោងកំណត់ ។

៤-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងចាត់ក្រុមអធិការកិច្ច ឲ្យធ្វើការត្រួតពិនិត្យអំពីការអនុវត្តវិធានការនេះជាបន្តបន្ទាប់ និងតាមការចាំបាច់ ។

**III-អំពីការទទួលខុសត្រូវ**

១-សាលារាជធានី ខេត្ត ត្រូវចេញសេចក្តីសម្រេចប្រគល់សិទ្ធិកាន់កាប់ និងលិខិតអនុញ្ញាតឲ្យភាគីឯកជនធ្វើអាជីវកម្ម សេវាកម្មលើទីតាំងទាំងនោះ ។

២-សាលារាជធានី ខេត្ត និងអង្គភាពសាមី ត្រូវគោរពអនុវត្តឱ្យបានម៉ឺងម៉ាត់បំផុត ទៅតាមលក្ខខណ្ឌដែលមានចែងនៅក្នុងសៀវភៅបន្ទុក ឬកិច្ចសន្យា និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាជាធរមាន ។

៣-ក្នុងករណីកើតមានបាតុភាពជាយថាហេតុជុំវិញការអនុវត្តសៀវភៅបន្ទុក ឬកិច្ចសន្យា នៃការធ្វើអាជីវកម្មសេវាកម្ម សាលារាជធានី ខេត្ត និងអង្គភាពសាមីពាក់ព័ន្ធ ត្រូវទទួលខុសត្រូវ ដោយផ្ទាល់។

៤-មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត និងទីចាត់ការហិរញ្ញវត្ថុសាលារាជធានី ខេត្ត ជាអ្នកគ្រប់គ្រង តាមដាន និងប្រមូលចំណូលនេះ ។ ដោយឡែក មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវបូកសរុបរាយការណ៍ឲ្យបានទៀងទាត់ នៅរៀងរាល់ខែយ៉ាងយូរត្រឹមថ្ងៃទី០៥ នៃខែបន្ទាប់ជាកំហិតរួចផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ) ដើម្បីអនុវត្តតាមមុខការរបស់ខ្លួន ។

៥-សមត្ថកិច្ចពាក់ព័ន្ធណា ដែលបណ្តែតបណ្តោយឲ្យភាគីឯកជនរំលោភបំពានលក្ខខណ្ឌនៅក្នុងសៀវភៅបន្ទុក ឬកិច្ចសន្យា ដូចជា ការយកថ្លៃលើសការកំណត់ជាដើម ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ។

៦-សាលារាជធានី ខេត្ត និងអង្គភាពសាមី ត្រូវចុះត្រួតពិនិត្យជាប្រចាំអំពីការអនុវត្តសៀវភៅបន្ទុក ឬកិច្ចសន្យា របស់ភាគីឯកជន ។ ក្នុងករណីពិនិត្យឃើញថា ភាគីឯកជនអនុវត្តខុសឆ្គងពីលក្ខខណ្ឌកំណត់នៅក្នុងសៀវភៅបន្ទុក ឬកិច្ចសន្យា ត្រូវមានការណែនាំអំពីកំហុសឆ្គងនោះ។ ករណីបានធ្វើការណែនាំហើយ ប៉ុន្តែភាគីឯកជននៅតែប្រព្រឹត្តល្មើស នោះសាលារាជធានី ខេត្ត និងអង្គភាពសាមី ត្រូវមានវិធានការតឹងរឹងតាមលក្ខខណ្ឌដែលមានចែងក្នុងសៀវភៅបន្ទុក ឬកិច្ចសន្យា និងទទួលពិន័យ ដូចខាងក្រោម ៖

-ល្មើសលើកទី១: ត្រូវពិន័យ ២០% នៃទឹកប្រាក់សរុបដែលត្រូវបង់ជូនរដ្ឋក្នុង១លើកៗ

-ល្មើសលើកទី២: ត្រូវពិន័យ ៥០% នៃទឹកប្រាក់សរុបដែលត្រូវបង់ជូនរដ្ឋក្នុង១លើកៗ

-ករណីរឹងរូសមិនរាងចាល ត្រូវពិន័យជាចុងក្រោយ គឺត្រូវដកហូតសិទ្ធិកាន់កាប់ធ្វើអាជីវកម្ម សេវាកម្ម រឹបអូសប្រាក់កក់ធានាបង់ចូលថវិការាជធានី ខេត្ត ហើយសៀវភៅបន្ទុក ឬកិច្ចសន្យា ត្រូវលុបចោលជាស្វ័យប្រវត្តិ ។ ក្នុងករណីមានកំហុសឆ្គងធ្ងន់ធ្ងរ សាលារាជធានី ខេត្ត និងអង្គភាពសាមី ត្រូវចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន ។ អ្នកប្រព្រឹត្តល្មើសមិនអនុញ្ញាតឲ្យចូលដេញថ្លៃ ឬសុំសិទ្ធិធ្វើអាជីវកម្ម សេវាកម្មនានា លើទ្រព្យសម្បត្តិរដ្ឋរយៈពេល ៣ឆ្នាំ ជាប់ៗគ្នា ។

៧-សាលារាជធានី ខេត្ត ត្រូវណែនាំភាគីឯកជនឲ្យដាក់ស្លាក សេចក្តីជូនដំណឹងអំពីថ្លៃ (ភាស៊ី ឬថ្លៃសេវា) និងប្រអប់សំបុត្រព័ត៌មានជាប់ជាប្រចាំ ដូចមានចែងក្នុងសៀវភៅបន្ទុក ដោយបិទនៅមាត់ច្រកចេញ-ចូល ដើម្បីងាយស្រួលឲ្យអតិថិជនបានឃើញ ជៀសវាងការទារតម្លៃសេវាលើសការកំណត់ ។ ប្រសិនបើភាគីឯកជនមិនបានអនុវត្តតាម ត្រូវចាត់វិធានការដូចក្នុងចំណុច ៦ ខាងលើ។

៨-ភាគីឯកជន ត្រូវធានាអនុវត្តឲ្យបានត្រឹមត្រូវតាមខ្លឹមសារសៀវភៅបន្ទុក ឬកិច្ចសន្យា ហើយត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

## IV-អំពីការបញ្ជាក់សុពលភាព និងការពិន័យ

១-ការបញ្ជាក់ដោយត្រឹមត្រូវក្នុងការអនុវត្តសៀវភៅបន្ទុក ឬកិច្ចសន្យា របស់ភាគីឯកជនគឺ៖

-ករណីជាទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ

-ករណីជាទ្រព្យសម្បត្តិរបស់ឯកជន ត្រូវទទួលនិងចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ តាមលក្ខខណ្ឌដែលមានចែងក្នុងសៀវភៅបន្ទុក ឬកិច្ចសន្យា ។

សាលារាជធានី ខេត្ត មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត និងអង្គភាពសាមី ត្រូវធ្វើការប្រគល់ទទួលទ្រព្យសម្បត្តិទាំងនោះឲ្យបានត្រឹមត្រូវពីភាគីឯកជន និងធ្វើការកត់ត្រាចុះក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

២- ករណីការបញ្ចប់សុពលភាពមុនកាលកំណត់៖

-ចំពោះភាគីឯកជនណាដែលបានប្រព្រឹត្តល្មើសធ្ងន់ធ្ងរ ត្រូវដកសិទ្ធិនិងលុបសៀវភៅបន្ទុក ឬ កិច្ចសន្យា ធ្វើអាជីវកម្ម សេវាកម្ម ឬការវិនិយោគលើទ្រព្យសម្បត្តិរបស់រដ្ឋ (ឬឯកជន) ហើយ សាលារាជធានី ខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវរៀបចំដាក់ដេញថ្លៃ ជាសាធារណៈតាមនីតិវិធីជាធរមាន ។

-អ្នកប្រព្រឹត្តល្មើសមិនអនុញ្ញាតឲ្យចូលដេញថ្លៃ ឬសុំសិទ្ធិជួលទ្រព្យសម្បត្តិរដ្ឋរយៈពេល ៣ឆ្នាំ ជាប់ៗគ្នា ។ ក្នុងករណីមានកំហុសធ្ងន់ធ្ងរ សាលារាជធានី ខេត្ត និងអង្គភាពសាមី ត្រូវចាត់ វិធានការតាមផ្លូវច្បាប់ជាធរមាន ។

ទទួលបានសារាចរណែនាំនេះ សាលារាជធានី ខេត្ត និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង ត្រូវអនុវត្ត និងផ្សព្វផ្សាយឲ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ
- សាលារាជធានី ខេត្ត
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត
- មន្ទីរជំនាញពាក់ព័ន្ធ
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ